ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ១៧០ MOC / M 2005

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០០៥

## <u>ប្រកាស</u>

## ស្តីពី ស្ថានភាពរោងចក្រកាត់ដេរ
## SAM HAN CAMBODIA FABIRC CO., LTD.

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមតំរូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## <u>សំរេច</u>

**<u>ប្រការ</u> ១ :** ចាត់ទុកថាបាន **បិទទ្វារជាបណ្តោះអាសន្ន** រោងចក្រកាត់ដេរសំលៀកបំពាក់ SAM HAN CAMBODIA FABRIC CO., LTD. ដែលគ្មានសកម្មភាពចំពោះមុខដោយមានមូលហេតុផ្សេងៗ ប៉ុន្តែ ឧបករណ៍ផលិតកម្ម និង គ្រឿងម៉ាស៊ីននៅរក្សាដដែលហើយកម្មករត្រូវបានបញ្ឈប់ពីការងារជា បណ្តោះអាសន្ន ។ រោងចក្រកាត់ដេរសំលៀកបំពាក់នោះនឹងត្រូវលុបចេញពីតារាង MFN/GSP នៃអ្នក មានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ រោងចក្រខាងលើនេះ អាចទទួលបានសិទ្ធ នាំចេញសាជាថ្មី ប្រសិនបើរោងចក្រនោះបន្តសកម្មភាពរបស់ខ្លួនវិញក្នុងរយៈពេល ៣ ខែបន្ទាប់ ។

ប្រសិនបើរោងចក្រនោះមិនបានបន្តសកម្មភាពរបស់ ខ្លួនក្នុងរយៈពេល ៣ ខែបន្ទាប់ រោងចក្រនោះនឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវឆូតពណ៌ក្រហម និង ចារថាបាន បិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , នាយកដ្ឋាននិតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតិយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម, នាយិកាខុទ្ទកាល័យ , និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *ស ខេង*
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *ហោ ណាំហុង*
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវៈនិតិសម្បទា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

File: Prakas on Temporarily Closed Sam Han Cambodia Fabric Co., Ltd./Cab-Sokpo/NC/Khmer.Doc



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
URL : http://www.moc.gov.kh E-Mail : moccabdir@yahoo.com
Senior Minister's Cabinet Mobile Phones: (855-12) 933 323 / 881 223 Facsimile: (855-23) 426 396 / 213 288 / 991 708